# ព្រះរាជក្រម

នស/រកម/០២៩៦/១៦

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្ដម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្ដីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីសម្ដេចនាយករដ្ឋមន្ត្រីទាំងពីរ

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

# ការបង្កើតក្រសួងពាណិជ្ជកម្ម

**មាត្រា ១.-**

ត្រូវបានបង្កើតក្រសួងពាណិជ្ជកម្មចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២.-**

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យពាណិជ្ជកម្មក្នុងនិងក្រៅប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងពាណិជ្ជកម្មត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបដែលអាចអមដោយរដ្ឋលេខាធិការ និង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ត្រូវកំណត់ដោយ អនុក្រឹត្យ ។

**មាត្រា ៥.-**

បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**